អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**ការិយាល័យរដ្ឋបាល**

ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣

# សេចក្តីប្រកាសព័ត៌មាន

## ជនជាប់ចោទ អៀង សារី បានទទួលមរណភាព

ជាមួយសេចក្តីសោកស្តាយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សូមប្រកាសជូនដំណឹងអំពីមរណភាពរបស់ជនជាប់ចោទ អៀង សារី។ លោក អៀង សារី បានស្លាប់នៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅព្រឹកថ្ងៃនេះ បន្ទាប់ពីបានចូលសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យនៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣។ អនុលោមតាមវិធាន ៣២ ស្ទួននៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហព្រះរាជអាជ្ញានឹងបញ្ជាក់អំពីមូលហេតុពិតប្រាកដនៃការស្លាប់នេះ បន្ទាប់ពីបានធ្វើការ ស៊ើបអង្កេតពាក់ព័ន្ធនានា។ សហព្រះរាជអាជ្ញានឹងចេញរបាយការណ៍ជាលាយលក្ខណ៍អក្សរមួយអំពីការរកឃើញរបស់គាត់នៅក្នុងពេលឆាប់ៗខាងមុខនេះ។

លោក អៀង សារី កើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩២៥ មានតួនាទីជាអតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស និងជាសមាជិកមួយរូបនៃគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អៀង សារី ត្រូវបានចាប់ខ្លួននៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០០៧ ហើយត្រូវបានជំនុំជម្រះក្តីនៅចំពោះមុខ អ.វ.ត.ក ចំពោះបទចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពារបំពាន យ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។

លោក អៀង សារី ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យជាច្រើនលើករួចមកហើយចាប់តាំងពីគាត់ត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំងបណ្តោះអាសន្នរបស់ អ.វ.ត.ក ហើយការវាយតម្លៃទៅលើកាយសម្បទា និងបញ្ញាស្មារតីក្នុងការចូលរួមសវនាការមួយគ្រោងនឹងធ្វើឡើងដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រជាតិ និងអន្តរជាតិនៅចុងខែមីនានេះ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិកៈ olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh